**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ :** ១៩ ............ **អយក** . សណវ

## សេចក្តីណែនាំចំពោះបេក្ខជន
## ក្នុងការបំពេញ និងដាក់ពាក្យសុំអាហារូបករណ៍

**យោង:** សេចក្តីជូនដំណឹងលេខ ១២ អយក.សជណ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ឱ្យចូលរៀនថ្នាក់បរិញ្ញាបត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន សម្រាប់ឆ្នាំសិក្សា២០១៤-២០១៥។

ដើម្បីបំពេញខ្លឹមសារក្នុងសំណុំពាក្យឲ្យបានត្រឹមត្រូវ បេក្ខជនត្រូវធ្វើតាមការណែនាំដូចមានខាងក្រោម:

១-មុននឹងសម្រេចសរសេរខ្លឹមសារចូលក្នុងសំណុំពាក្យ បេក្ខជនត្រូវគិតពិចារណាឱ្យបានច្បាស់លាស់ដោយធ្វើការសិក្សាលើគ្រប់ចំណុចដែលមានក្នុងសៀវភៅកម្រងព័ត៌មាន។ ក្នុងករណីមិនយល់ពីចំណុចណាមួយ អាចសាកសួរមន្ត្រីដែលទទួលបន្ទុកទទួលពាក្យនៅតាមវិទ្យាល័យ ឬនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ឬទំនាក់ទំនងជាមួយនាយកដ្ឋានឧត្តមសិក្សា ទូរស័ព្ទលេខ **០២៣ ២១៧ ៩៣៧** ឬជាមួយគ្រឹះស្ថានឧត្តមសិក្សា ដែលបេក្ខជនបានដាក់ពាក្យសុំអាហារូបករណ៍ ដែលមានលេខទូរស័ព្ទនៅក្នុងសៀវភៅកម្រងព័ត៌មាន។

២-បេក្ខជនត្រូវសរសេរបំពេញសំណុំពាក្យរបស់ខ្លួនឲ្យបានគ្រប់ចំណុចត្រឹមត្រូវតាមការពិត និងច្បាស់លាស់ និងត្រូវផ្តល់ឯកសារភ្ជាប់បន្ថែមឱ្យបានគ្រប់ចំនួនតាមការកំណត់។ ចំពោះបេក្ខជនដែលសរសេរបំពេញមិនបានត្រឹមត្រូវក្នុងសំណុំពាក្យ មិនគ្រប់តាមចំណុច ឬផ្តល់ឯកសារបន្ថែមមិនគ្រប់គ្រាន់ **សំណុំពាក្យរបស់បេក្ខជននោះត្រូវបានចាត់ទុកថាពុំបានការ ។**

៣-បេក្ខជនចំណេះទូទៅ និងបំពេញវិជ្ជាដែលត្រូវប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ ២០១៤ ត្រូវបំពេញលេខតុឆមាសរបស់ខ្លួនឱ្យបានត្រឹមត្រូវលើសំណុំពាក្យសុំអាហារូបករណ៍ ។ ចំពោះបេក្ខជនដែលបាន**ផ្ទេរការសិក្សាត្រូវសុំលេខតុឆមាសថ្មីនៅវិទ្យាល័យថ្មីរបស់ខ្លួនពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-រាជធានី ដែលគ្រប់គ្រងវិទ្យាល័យថ្មីនេះ។** ចំពោះបេក្ខជនស្វ័យរិន ក៏ត្រូវសុំមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-រាជធានីឱ្យចុះលេខរៀង ដែលមានក្នុងបញ្ជីបេក្ខភាពផងដែរ។

៤-បេក្ខជនអាចស្នើសុំអាហារូបករណ៍ ក្នុងប្រភេទសិស្សអាទិភាពតំបន់ដាច់ស្រយាលបាន **លុះត្រាតែមានដើមកំណើត និងបានរៀនសូត្រនៅខេត្តរតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ឧត្តរមានជ័យ ព្រះវិហារ កោះកុង និងខេត្តប៉ៃលិន និងនៅតំបន់មួយចំនួនទៀតដែលជួបការលំបាកដូចមានចែងក្នុងឧបសម្ព័ន្ធក្នុងសៀវភៅកម្រងព័ត៌មាន។**

៥-ចំពោះបេក្ខជនដាក់ស្នើសុំអាហារូបករណ៍ក្នុងប្រភេទអាទិភាពក្រីក្រ ជាប់ហើយក្រោយការចុះផ្ទៀងផ្ទាត់របស់ក្រសួងអប់រំ យុវជន និងកីឡាឃើញថាមិនពិត ក្រសួងអប់រំ យុវជន និងកីឡានឹងដកអាហារូបករណ៍ ចេញពីបេក្ខជនដែលបន្លំព័ត៌មាន ហើយបេក្ខជននោះនឹងត្រូវប្រឈមចំពោះមុខច្បាប់។

៦-បេក្ខជនអាចដាក់ស្នើសុំប្រភេទអាហារូបករណ៍ចាប់ពី២ឡើងទៅ។

**ឧទាហរណ៍៖ អាទិភាពនារី អាទិភាពក្រីក្រ។**



អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ៤២៧ ៣៥៦ / ៤២៦ ៩៥១ / ២១២ ៥១២
E-mail: crsmeys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh

៧-ការជ្រើសរើសមហាវិទ្យាល័យ ឬដេប៉ាតឺម៉ង់ ឬផ្នែក ឬមុខជំនាញៈ បេក្ខជនត្រូវសរសេរឈ្មោះមហាវិទ្យាល័យ ឬដេប៉ាតឺម៉ង់ ឬផ្នែក ឬមុខជំនាញតែមួយដែលមានក្នុងសៀវភៅកម្រងព័ត៌មាន និងចុះលេខរៀង មហាវិទ្យាល័យ ឬដេប៉ាតឺម៉ង់ ឬផ្នែក ឬមុខជំនាញនោះ ឱ្យបានត្រឹមត្រូវជាលេខអារ៉ាប់ទៅលើសន្លឹកពាក្យសុំអាហារូបករណ៍ និងបង្កាន់ដៃទទួលពាក្យសុំអាហារូបករណ៍ឱ្យដូចគ្នា។

ឧទាហរណ៍៖

| មហាវិទ្យាល័យ/ដេប៉ាតឺម៉ង់/ផ្នែក/មុខជំនាញ | លេខរៀង (ល.រ) |
|---|---|
| អក្សរសាស្ត្រខ្មែរ | 8 |

៨- ក្នុងករណីដែលបេក្ខជនបំពេញព័ត៌មានពីការជ្រើសរើសអាទិភាពលើពាក្យសុំអាហារណ៍ និងបង្កាន់ដៃទទួលពាក្យសុំអាហារូបករណ៍មិនដូចគ្នា ឬសរសេរទឹកប៊ិចផ្សេងគ្នា សំណុំពាក្យនោះនឹងត្រូវចាត់ទុកជាពុំបានការ។

៩-ចំពោះបេក្ខជនដែលបានដាក់ពាក្យសុំអាហារូបករណ៍ សិក្សាមុខជំនាញដែលតម្រូវឲ្យមានការប្រឡងសំណេរ ត្រូវយកសលាកបត្រឯកត្តជនពីវិទ្យាល័យមកបំពេញខ្លឹមសារ និងបិទរូបថតឱ្យបានត្រឹមត្រូវ ។ សលាកបត្រនេះត្រូវដកយកមកប្រគល់ឱ្យគ្រឹះស្ថានឧត្តមសិក្សា ដែលខ្លួនដាក់ពាក្យសុំប្រឡងអាហារូបករណ៍ណាមួយដូចមានខាងលើជាកំហិត ចាប់ពីថ្ងៃទី០៤ ដល់ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ ចំនួន០១ច្បាប់ និង០១ច្បាប់ទៀតរក្សាទុកជាប់នឹងខ្លួន សម្រាប់បង្ហាញគណៈមេប្រយោគប្រឡងនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៤ នៅមណ្ឌលប្រឡង។ **ករណីមិនបានប្រគល់សលាកបត្រតាមការកំណត់នេះទេ នោះបេក្ខជនពុំអាចចូលប្រឡងបានឡើយ។** បេក្ខជនត្រូវមកមើលឈ្មោះប្រឡងនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ ចាប់ពីម៉ោង ២:០០នាទី រសៀល នៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលខ្លួនស្នើសុំអាហារូបករណ៍។

១០-សិស្សពូកែទូទាំងប្រទេសផ្នែកគណិតវិទ្យា រូបវិទ្យា និងអក្សរសិល្ប៍ខ្មែរ ដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤ មានសិទ្ធិជាប់អាហារូបករណ៍ដោយស្វ័យប្រវត្តិចំនួន**មួយកន្លែង** ចូលរៀនតាមផ្នែកពូកែរបស់ខ្លួនដូចមានការកំណត់ក្នុងសៀវភៅកម្រងព័ត៌មានដែលមានសញ្ញាផ្កាយ លក្ខខណ្ឌមុខវិជ្ជានិទ្ទេសតាមមុខវិជ្ជា និទ្ទេសរួម និងចំនួនជ្រើសរើសនិស្សិតអាហារូបករណ៍សម្រាប់ឆ្នាំសិក្សា ២០១៤-២០១៥ ។ សិទ្ធិនេះត្រូវបានរក្សាទុកនៅពេលណាសិស្សពូកែទាំងនោះ បានមកដាក់ពាក្យសុំអាហារូបករណ៍នៅតាម**មន្ទីរអប់រំ យុវជន និងកីឡា ចាប់ពីថ្ងៃទី២៧ ខែឧសភា ដល់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤**។ ក្នុងករណីសិស្សពូកែទូទាំងប្រទេសមិនចង់ទទួលអាហារូបករណ៍ដោយស្វ័យប្រវត្តិដូចដែលបានកំណត់ក្នុងកូនសៀវភៅកម្រងព័ត៌មាន សិស្សពូកែទាំងនោះត្រូវដាក់ពាក្យសុំអាហារូបករណ៍នៅតាមវិទ្យាល័យ ឬតាមមន្ទីរអប់រំ យុវជន និងកីឡា ដូចជាសិស្សទូទៅដែរ។

១១-ការប្រគល់សំណុំពាក្យត្រឡប់ឱ្យទៅវិទ្យាល័យ ឬឱ្យទៅមន្ទីរអប់រំ យុវជន និងកីឡាវិញ មិនបានទាន់ពេលវេលាតាមការកំណត់ ត្រូវបានចាត់ទុកថា បេក្ខជននោះបានបោះបង់បេក្ខភាពរបស់ខ្លួន។

១២-សំណុំពាក្យដែលបេក្ខជនបានបំពេញខ្លឹមសាររួចហើយ និងបានប្រគល់មកដល់នាយកដ្ឋានឧត្តមសិក្សារួចហើយ នោះពុំអាចស្នើសុំយកទៅកែ ឬផ្លាស់ប្តូរខ្លឹមសារបានឡើយ។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា បេក្ខជនទាំងពីរភេទដែលកំពុងត្រៀមខ្លួនស្នើសុំអាហារូបករណ៍ចូលរៀនថ្នាក់បរិញ្ញាបត្រសម្រាប់ឆ្នាំសិក្សា ២០១៤-២០១៥ នៅតាមគ្រឹះស្ថានឧត្តមសិក្សា នឹងអនុវត្តតាមសេចក្តី-ណែនាំនេះដោយស្មារតីយកចិត្តទុកដាក់បំផុត។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

យក់ ឌុំយ